AIA សម្រាប់សុខភាព

ដំណោះស្រាយសុខភាព ពេញមួយជីវិតដំបូងគេនៅកម្ពុជា



សុខភាព និងជីវិត
កាន់តែប្រសើរ

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាព

សុខភាពរបស់លោកអ្នកគឺជាទ្រព្យដ៏មានតម្លៃបំផុត! ហេតុដូចនេះ លោកអ្នកគួរតែទទួលបានការការពារដ៏ល្អបំផុតនៅពេលដែលលោកអ្នកគិតគូរពីសុខភាពផ្ទាល់ខ្លួន។ ការរៀបចំគម្រោងហិរញ្ញវត្ថុសម្រាប់សុខភាពដ៏ត្រឹមត្រូវពិតជាមានសារៈសំខាន់ ហើយអាចផ្តល់នូវការការពារដល់លោកអ្នកតាមតម្រូវការយ៉ាងពេញលេញ។ លោកអ្នកអាចជានាបានថា ការចំណាយផ្ទាល់ខ្លួនលើការព្យាបាលជំងឺមានចំនួនតិចតួចបំផុត ដែលអាចជួយសម្រាលបន្ទុកលើការចំណាយ តាំងពីការធ្វើរោគវិនិច្ឆ័យ រហូតដល់ការព្យាបាលជាសះស្បើយឱ្យបានទាន់ពេលវេលា។

ហេតុអ្វី AIA សម្រាប់សុខភាព ជាជម្រើសដ៏សំខាន់សម្រាប់លោកអ្នក?

AIA សម្រាប់សុខភាព គឺជាគម្រោងធានារ៉ាប់រងផ្នែកសុខភាព ជួយសម្រួលថ្លៃចំណាយលើការថែរក្សាសុខភាពស្របតាមតម្រូវការក្នុងរយៈពេលវែងពេញមួយជីវិត ដែលផ្តល់ការការពារចាប់ពីតាំងពីការបង្ការជំងឺ រហូតដល់ការព្យាបាលឱ្យជាសះស្បើយឡើងវិញ។ គម្រោងនេះផ្តល់ការការពារជូនលោកអ្នកតាំងពីដំបូង ជាមួយនឹងអត្ថប្រយោជន៍ជាច្រើន ដែលមានទាំងការចំណាយលើការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងការវះកាត់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ រួមទាំងការព្យាបាលជំងឺមុនចូលសម្រាកក្នុងមន្ទីរពេទ្យ និងក្រោយការសម្រាកក្នុងមន្ទីរពេទ្យ ដែលកើតឡើងដោយសារជំងឺ ឬគ្រោះថ្នាក់ចៃដន្យ ការព្យាបាលជំងឺសង្គ្រោះបន្ទាន់ ព្រមទាំងការសម្រាលកូន និងអត្ថប្រយោជន៍ជាច្រើនទៀត ដើម្បីធានាថាសុខុមាលភាពរបស់លោកអ្នក គឺទទួលបានការមើលថែទាំយ៉ាងយកចិត្តទុកដាក់បំផុត។

គម្រោងធានារ៉ាប់រងសុខភាពពេញមួយជីវិត

ធានាបន្តសុពលភាពរហូតដល់អាយុ **100**ឆ្នាំ ជាមួយទំហំទឹកប្រាក់ធានារ៉ាប់រងរហូតដល់ **1.5**លានដុល្លារអាមេរិក

រង្វាន់លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង

សម្រាប់ការរស់នៅប្រកបដោយសុខភាពល្អ សម្រាប់ការប្រើប្រាស់លើការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការជំងឺផ្សេងៗ ការថែទាំសុខភាពមាត់ធ្មេញជាដើម

បណ្តាញមន្ទីរពេទ្យដែលប្រកបដោយគុណភាពទាំងក្នុងនិងក្រៅប្រទេស

- បណ្តាញមន្ទីរពេទ្យដែលប្រកបដោយគុណភាពទាំងក្នុង និងក្រៅប្រទេសជាមួយបទពិសោធន៍ទូទាត់ថ្លៃចំណាយដោយមិនប្រើសាច់ប្រាក់
- ការពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន និងការណែនាំអំពីមតិទីពីរពីអ្នកជំនាញវេជ្ជសាស្ត្រនៅក្រៅប្រទេស*

*សេវាកម្មនេះមិនរាប់បញ្ចូលថ្លៃធ្វើដំណើរ និងថ្លៃព្យាបាលទេ

គម្រោងដំណោះស្រាយសុខភាព

គម្រោង	គម្រោង 50K	គម្រោង 150K	គម្រោង 500K	គម្រោង 1M	គម្រោង 1.5M
ទីតាំងភូមិសាស្ត្រនៃការធានា	ប្រទេសកម្ពុជា ថៃ វៀតណាម និងម៉ាឡេស៊ី	ទូទាំងអាស៊ាន	ទូទាំងទ្វីបអាស៊ី	ទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក	ទូទាំងពិភពលោក មិនរាប់បញ្ចូលសហរដ្ឋអាមេរិក
កម្រិតអតិបរមាប្រចាំឆ្នាំសរុប (សម្រាប់ 1ឆ្នាំ)	US$50,000	US$150,000	US$500,000	US$1,000,000	US$1,500,000
កម្រិតអតិបរមាសរុបក្នុងមួយជីវិត	US$100,000	US$300,000	US$1,000,000	US$2,000,000	US$3,000,000
2 ជម្រើស					
ជម្រើសទី1៖ កម្រិតមិនធ្វើសំណង (ក្នុង 1ឆ្នាំ)	3 ជម្រើស៖ US$5,000 | US$10,000 | US$20,000				
ជម្រើសទី2៖ ការចូលរួមចំណែកនៃចំណាយ (សម្រាប់ 1ព្រឹត្តិការណ៍)	10%				មិនមាន
កម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន (សម្រាប់ 1ព្រឹត្តិការណ៍)	US$500	US$1,000	US$1,500	US$2,000	មិនមាន

អត្ថប្រយោជន៍លម្អិត					
(A) អត្ថប្រយោជន៍លើការសង្គ្រោះព្យាបាលក្នុងមន្ទីរពេទ្យ និងការវះកាត់					
(i) អត្ថប្រយោជន៍លើតម្លៃសោរបន្ទប់ និងត្រៃប្រចាំថ្ងៃ (រួមបញ្ចូលថ្លៃអាហារ) (រហូតដល់ 100 ថ្ងៃក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រងសម្រាប់អត្ថប្រយោជន៍លើតម្លៃសោរបន្ទប់ និងត្រៃប្រចាំថ្ងៃ និងអត្ថប្រយោជន៍លើការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់ប្រចាំថ្ងៃ)	រហូតដល់ US$50/ថ្ងៃ	រហូតដល់ US$100/ថ្ងៃ	រហូតដល់ US$200/ថ្ងៃ	រហូតដល់ US$300/ថ្ងៃ	រហូតដល់ US$400/ថ្ងៃ
(ii) អត្ថប្រយោជន៍លើការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់ប្រចាំថ្ងៃ (រួមបញ្ចូលថ្លៃអាហារ) (រហូតដល់ 100 ថ្ងៃក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រងសម្រាប់អត្ថប្រយោជន៍លើតម្លៃសោរបន្ទប់ និងត្រៃប្រចាំថ្ងៃ និងអត្ថប្រយោជន៍លើការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់ប្រចាំថ្ងៃ)	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ
(iii) អត្ថប្រយោជន៍លើការចំណាយផ្សេងទៀតដែលទាក់ទងនឹងការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ (រួមបញ្ចូលថ្លៃឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស ថ្លៃសេវាកម្មធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានស្ថានភាពជំងឺ សោរថៃទាំរបស់គិលានុបដ្ឋាយិកា និងថ្លៃចំណាយផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ)					
(iv) អត្ថប្រយោជន៍លើការវះកាត់ (រួមបញ្ចូលថ្លៃបន្ទប់វះកាត់ និងថ្លៃវេជ្ជបណ្ឌិតចាត់ថ្នាំសណ្តំ ដែលចាំបាច់តាមការកំណត់របស់វេជ្ជបណ្ឌិតជំនាញឯកទេស ឬវេជ្ជបណ្ឌិតជំងឺទូទៅ ឬអ្នកជំនាញ) • នីតិវិធីការវះកាត់ • ការវះកាត់ដាក់សម្ភារៈវេជ្ជសាស្ត្រដែលទទួលបានការអនុម័ត • ការវះកាត់ដោយប្រើប្រាស់បច្ចេកទេសនៃ Stereotactic Radiosurgery					
(v) អត្ថប្រយោជន៍លើការផ្លាស់ប្តូរសរីរាង្គសំខាន់ៗ ឬការផ្លាស់ប្តូរខួរឆ្អឹង					
(vi) អត្ថប្រយោជន៍លើគ្រែបន្ថែមសម្រាប់អាណាព្យាបាល ឬអ្នកកំដរ	មិនធានា				
(vii) អត្ថប្រយោជន៍លើការថៃទាំរបស់គិលានុបដ្ឋាកតាមផ្ទះ		មិនធានា	រហូតដល់ US$1,000/ឆ្នាំ	រហូតដល់ US$1,500/ឆ្នាំ	រហូតដល់ US$2,000/ឆ្នាំ
(viii) អត្ថប្រយោជន៍លើការថៃទាំជំងឺផ្លូវចិត្តសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ			បង់ជូនពេញថ្លៃ (រហូតដល់ 30 ថ្ងៃ ក្នុងមួយឆ្នាំ)		
(ix) អត្ថប្រយោជន៍លើការថៃទាំអ្នកជំងឺដំណាក់កាលចុងក្រោយសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ			មិនធានា	មិនធានា	រហូតដល់ US$20,000 ក្នុងមួយជីវិត
(B) អត្ថប្រយោជន៍លើការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ (កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ)	រហូតដល់ US$7,500	រហូតដល់ US$22,500	រហូតដល់ US$75,000	រហូតដល់ US$150,000	រហូតដល់ US$225,000
(i) អត្ថប្រយោជន៍លើការព្យាបាលជំងឺមុនចូលសម្រាកក្នុងមន្ទីរពេទ្យ (ដែលកើតឡើងក្នុងអំឡុងពេល 90 ថ្ងៃ មុនចូលសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូលថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញការធ្វើរោគវិនិច្ឆ័យដោយប្រើប្រាស់កាំរស្មីអ៊ិច ឬការធ្វើតេស្តពិសោធន៍)	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ	បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ
(ii) អត្ថប្រយោជន៍លើការព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ (ដែលកើតឡើងក្នុងអំឡុងពេល 90 ថ្ងៃ ក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូលថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញ ការព្យាបាលជំងឺដោយចលនាតាមវេជ្ជបញ្ជា ឬការធ្វើតេស្តពិសោធន៍)					
(iii) អត្ថប្រយោជន៍លើការវះកាត់ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ					
(iv) អត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីក • ការព្យាបាលជំងឺមហារីកដោយប្រើរ៉ឹស្សីសកម្ម (Radiotherapy) • ការព្យាបាលជំងឺមហារីកដោយការចាក់គីមី (Chemotherapy)					
(v) អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការលាងឈាម					
(C) អត្ថប្រយោជន៍លើការព្យាបាលជំងឺសង្គ្រោះបន្ទាន់					
(i) អត្ថប្រយោជន៍លើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ
(ii) អត្ថប្រយោជន៍លើការព្យាបាលធ្មេញដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ					
(ii) អត្ថប្រយោជន៍លើរថយន្តគិលានសង្គ្រោះបន្ទាន់					
(iv) អត្ថប្រយោជន៍លើការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ និងសេវាដឹកត្រលប់មកវិញ	មិនធានា	មិនធានា	មិនធានា	មិនធានា	

(D) អត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន					
(i) អត្ថប្រយោជន៍លើផលវិបាកក្នុងអំឡុងពេលមានផ្ទៃពោះ	រហូតដល់ US$2,000	រហូតដល់ US$5,000	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ	បង់ជូនពេញថ្លៃ
(ii) អត្ថប្រយោជន៍លើការសម្រាលកូន និងការថែទាំទារកទើបនឹងកើត	មិនធានា	មិនធានា	រហូតដល់ US$1,500	រហូតដល់ US$3,000	រហូតដល់ US$8,000
(E) អត្ថប្រយោជន៍លើការព្យាបាលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS)	មិនធានា	មិនធានា	មិនធានា	មិនធានា	បង់ជូនពេញថ្លៃ
(F) សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន (PMCM)	ធានា	ធានា	ធានា	ធានា	ធានា
(G) អត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង	មិនធានា	US$50	US$150	US$200	US$300
(i) អត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ • អត្ថប្រយោជន៍លើការពិនិត្យសុខភាពជាប្រចាំ • អត្ថប្រយោជន៍លើការត្រួតពិនិត្យរកជំងឺផ្សេងៗ • អត្ថប្រយោជន៍លើការចាក់ថ្នាំបង្ការ	មិនធានា	រហូតដល់ US$50	រហូតដល់ US$150	រហូតដល់ US$200	រហូតដល់ US$300
(ii) អត្ថប្រយោជន៍លើការថែទាំសុខភាពមាត់ធ្មេញ • អត្ថប្រយោជន៍លើការថែទាំ និងពិនិត្យសុខភាពមាត់ធ្មេញជាប្រចាំ					

លក្ខខណ្ឌដែលអាចទទួលយកការធានា

- **អ្នកត្រូវបានធានារ៉ាប់រង៖** អាយុ 30ថ្ងៃ – 69ឆ្នាំ
- **ម្ចាស់បណ្ណសន្យារ៉ាប់រង៖** ចាប់ពីអាយុ 18ឆ្នាំឡើងទៅ
- **បានទិញគម្រោងមូលដ្ឋានមួយពី ក្រុមហ៊ុន អេ អាយ អេ ដែលអនុញ្ញាតឱ្យភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងបន្ថែមនេះ។**

ការបង់បុព្វលាភធានារ៉ាប់រង

- **រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង៖** បន្តសុពលភាពប្រចាំឆ្នាំ រហូតអ្នកត្រូវបានធានារ៉ាប់រងអាយុ 100ឆ្នាំ
- **របៀបទូទាត់៖** ប្រចាំឆមាស ឬប្រចាំឆ្នាំ
- **មធ្យោបាយទូទាត់៖** មធ្យោបាយទូទាត់ទាំងអស់ដែលកំណត់ដោយក្រុមហ៊ុន **អេ អាយ អេ**
- **រយៈពេលអនុគ្រោះ៖** 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង

ការបង្ហាញជាឧទាហរណ៍ទី1

សុខភាពជាទ្រព្យ



លោក សុខ: ភាព អាយុ **35**ឆ្នាំ ជាអ្នកជំនួញ បានទទួលយកការការពារពីផលិតផល **"AIA សម្រាប់សុខភាព"** សម្រាប់កញ្ចប់ធានារ៉ាប់រងសុខភាពគម្រោង **500K (US$500,000)** ដោយភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋាន **"AIA ចម្បង"**។ រយៈពេលនៃការធានារ៉ាប់រងនិងរយៈពេលបង់បុព្វលាភធានារ៉ាប់រងសម្រាប់គម្រោងនេះមានរយៈពេលចំនួន **65**ឆ្នាំ។

ការចូលរួមចំណែកនៃចំណាយរបស់គាត់គឺ **10%** ជាមួយនឹងកម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួនចំនួន **US$1,500** (សម្រាប់ 1ព្រឹត្តិការណ៍)។ បុព្វលាភធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះក្នុងឆ្នាំទី1គឺ **US$1,604.3** ។

អាយុ **35**
សម្រាប់ឆ្នាំទី1 ដល់ឆ្នាំទី4 លោក **សុខ: ភាព** មិនបានទាមទារសំណង និងមានសុខភាពល្អប្រសើរ។
អាយុ **39**



លោក សុខ: ភាព ត្រូវបានរកឃើញថាមានជំងឺមហារីក និងទទួលការព្យាបាល។ ថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញចំណាយអស់ **US$200**។ បន្ទាប់មក គាត់ត្រូវតម្រូវឱ្យសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួន **10**ថ្ងៃ និងឆ្លងកាត់ការវះកាត់។ ការចំណាយសរុបអស់ **US$7,500** (រួមបញ្ចូលថ្លៃបន្ទប់ និងគ្រែសរុប **US$1,500** ថ្លៃឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស និងសេវាថែទាំរបស់គិលានុបដ្ឋាយិកា សរុប **US$1,000** ថ្លៃវះកាត់ **US$5,000**)។ **លោក សុខ: ភាព** ត្រូវព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យក្នុងអំឡុងពេល **90**ថ្ងៃ និងទទួលការព្យាបាលជំងឺមហារីកដោយការចាក់គីមីរយៈពេល **6**ខែ។ គាត់បានចំណាយអស់ **US$5,000** លើការព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ និងចំណាយអស់ **US$6,000** លើការព្យាបាលជំងឺមហារីកដោយការចាក់គីមី។

តារាងអត្ថប្រយោជន៍លើការព្យាបាលផ្នែកវេជ្ជសាស្ត្រដែលផ្តល់ជូនទៅកាន់ លោក សុខ: ភាព

ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង	ចំណាយជាក់ស្តែង	អត្ថប្រយោជន៍ផ្តល់ជូន
អត្ថប្រយោជន៍លើការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ • តម្លៃសេវាបន្ទប់និងគ្រែប្រចាំថ្ងៃ	US$1,500 (10ថ្ងៃ)	US$1,500 (10ថ្ងៃ x US$150)
អត្ថប្រយោជន៍លើការចំណាយផ្សេងទៀតដែលទាក់ទងនឹងការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ • ថ្លៃឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស និងសេវាថែទាំរបស់គិលានុបដ្ឋាយិកា សេវាបន្ទប់ និងគ្រែប្រចាំថ្ងៃ	US$1,000	US$1,000
អត្ថប្រយោជន៍លើការវះកាត់ • នីតិវិធីការវះកាត់	US$5,000	US$5,000
អត្ថប្រយោជន៍លើការព្យាបាលជំងឺមុនចូលសម្រាកក្នុងមន្ទីរពេទ្យ • ថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញ	US$200	US$200
អត្ថប្រយោជន៍លើការព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ • ការព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ	US$5,000	US$5,000
អត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីកដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ • ការព្យាបាលជំងឺមហារីកដោយការចាក់គីមី (Chemotherapy)	US$6,000	US$6,000
ទឹកប្រាក់សរុបដែលត្រូវបង់	US$18,700	US$18,700
ការចូលរួមចំណែកនៃចំណាយ (10%)		US$1,870
កម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន		US$1,500
អត្ថប្រយោជន៍សរុបដែលត្រូវបង់ បន្ទាប់ពីការចូលរួមចំណែកនៃចំណាយ		US$17,200
កម្រិតអត្ថប្រយោជន៍ដែលនៅសល់		US$482,800

លោក សុខ: ភាព នៅបន្តទទួលបានការការពារផ្នែកសុខភាពរហូតដល់អាយុ 100ឆ្នាំ។

ការបង្ហាញជាឧទាហរណ៍ទី2

បង្កើនការការពារផ្នែកសុខភាពដ៏ពេញលេញជាមួយតម្លៃបុព្វលាភធានារ៉ាប់រងសមរម្យ



លោកស្រី សុខ សាន្ត មានអាយុ 26ឆ្នាំ ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយរូប។ គាត់បានទិញធានារ៉ាប់រងសុខភាពដែលមានឈ្មោះថា **"AIA សម្រាប់សុខភាព"** ដោយភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋាន **"AIA ចម្បង"**។

គាត់បានជ្រើសរើសកម្រិតមិនធ្វើសំណងចំនួន US$5,000 សម្រាប់កញ្ចប់ធានារ៉ាប់រងសុខភាពគម្រោង 50K (US$50,000) បន្ថែមពីលើគម្រោងធានារ៉ាប់រងសុខភាពមានស្រាប់ដែលក្រុមហ៊ុនរបស់គាត់បានទិញឱ្យរួចហើយ។ រយៈពេលនៃការធានារ៉ាប់រង និងរយៈពេលបង់បុព្វលាភធានារ៉ាប់រងសម្រាប់គម្រោងនេះមានរយៈពេល 74ឆ្នាំ។ បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះក្នុងឆ្នាំទី1 គឺ US$114.2។

អាយុ 26
សម្រាប់ឆ្នាំទី1 ដល់ឆ្នាំទី2 លោកស្រី **សុខ សាន្ត** មិនបានទាមទារសំណង និងមានសុខភាពល្អប្រសើរ។
អាយុ 28



លោកស្រី សុខ សាន្ត បានសម្រាកព្យាបាលក្នុងមន្ទីរពេទ្យដោយសារជំងឺធ្ងន់ធ្ងរចំនួន 10ថ្ងៃ។ ចំណាយសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរបស់គាត់គឺចំនួន US$50/ថ្ងៃ ថ្លៃឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស ថ្លៃសេវាកម្មធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានស្ថានភាពជំងឺ និងសេវាថែទាំរបស់គិលានុបដ្ឋាយិកាសរុបចំណាយអស់ US$2,500 និងថ្លៃចំណាយលើការវះកាត់ចំនួន US$10,000។

លោកស្រី សុខ សាន្ត បានទាមទារសំណងចំនួន US$5,000 ពីគម្រោងធានារ៉ាប់រងសុខភាព ដែលក្រុមហ៊ុនគាត់បានទិញឱ្យ

ក្រុមហ៊ុន អេ អាយ អេ នឹងដោះស្រាយជូនថ្លៃចំណាយដែលនៅសល់លើការព្យាបាលផ្នែកវេជ្ជសាស្ត្រ ជូនទៅកាន់ លោកស្រី សុខ សាន្ត

ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង	ចំណាយជាក់ស្តែង	អត្ថប្រយោជន៍ផ្តល់ជូន
អត្ថប្រយោជន៍លើការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ • តម្លៃសេវាបន្ទប់ និងគ្រែប្រចាំថ្ងៃ	US$500 (US$50 x 10ថ្ងៃ)	US$500 (US$50 x 10ថ្ងៃ)
អត្ថប្រយោជន៍លើការចំណាយផ្សេងទៀតដែលទាក់ទងនឹងការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ • ថ្លៃឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស ថ្លៃសេវាកម្មធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានស្ថានភាពជំងឺ និងសេវាថែទាំរបស់គិលានុបដ្ឋាយិកា	US$2,500	US$2,500
អត្ថប្រយោជន៍លើការវះកាត់ • នីតិវិធីការវះកាត់	US$10,000	US$10,000
ទឹកប្រាក់សរុបដែលត្រូវបង់	US$13,000	US$13,000
កម្រិតមិនធ្វើសំណង		US$5,000
អត្ថប្រយោជន៍សរុបដែលត្រូវបង់ បន្ទាប់ពីកម្រិតមិនធ្វើសំណង		US$8,000
កម្រិតអត្ថប្រយោជន៍ដែលនៅសល់		US$42,000

លោកស្រី សុខ សាន្ត នៅបន្តទទួលបានការការពារផ្នែកសុខភាពរហូតដល់អាយុ 100ឆ្នាំ។

ការទាមទារសំណង

ប្រសិនបើលោកអ្នកចង់ធ្វើការទាមទារសំណង លោកអ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងអំឡុងពេល 90ថ្ងៃ ពីថ្ងៃកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ លោកអ្នកអាចទាញយកទម្រង់បែបបទទាមទារសំណងពីគេហទំព័ររបស់យើង aia.com.kh ឬពី **ទីប្រឹក្សាផែនការជីវិត អេ អាយ អេ**។

រាល់ឯកសារនិងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ **ក្រុមហ៊ុន អេ អាយ អេ** ខេមបូឌា មានដូចជា វិក្កយបត្រច្បាប់ដើម វិញ្ញាបនបត្រវេជ្ជសាស្ត្រ របាយការណ៍ចេញពីមន្ទីរពេទ្យ និងឯកសារវេជ្ជសាស្ត្រផ្សេងទៀត។ ប្រសិនបើកាលបរិច្ឆេទនៃការចូលមន្ទីរពេទ្យ និងកាលបរិច្ឆេទចេញពីមន្ទីរពេទ្យ គឺនៅក្នុងថ្ងៃតែមួយនោះ នៅលើរបាយការណ៍ចេញពីមន្ទីរពេទ្យ ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រ សេចក្តីសង្ខេបត្រូវតែ បញ្ជាក់អំពីកាលបរិច្ឆេទ និងពេលវេលា។ រាល់ឯកសារវេជ្ជសាស្ត្រទាំងអស់ត្រូវទទួលបានពីមណ្ឌលសុខភាពដែលមានអាជ្ញាបណ្ណស្របច្បាប់ក្នុងការផ្តត់ផ្គង់ការព្យាបាលនៅក្នុងប្រទេស។ អ្នកទាមទារសំណងអាចស្នើសុំសំណងប្រសិនបើករណីត្រូវទាមទារសំណងកើតឡើងក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

ទទួលយកសំណើធានារ៉ាប់រងរបស់អ្នកថ្ងៃនេះ

សូមទាក់ទង ទីប្រឹក្សាផែនការជីវិត អេ អាយ អេ ឬសេវាបម្រើអតិថិជន អេ អាយ អេ Client Care

- លេខទូរសព្ទ ៖ 086 999 242
- អ៊ីម៉ែល ៖ KH.Care@aia.com
- គេហទំព័រ ៖ aia.com.kh
- តេឡេក្រាម ៖ AIACambodia bot

ករណីមិនធានា

AIA សម្រាប់សុខភាព មិនធានាលើចំណាយដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពី៖

1. ស្ថានភាពមុនពេលធានារ៉ាប់រងណាមួយដែលបានកើតឡើងមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ឬកាលបរិច្ឆេទចុងក្រោយគេនៃគម្រោងដែលបានផ្លាស់ប្តូរថ្មីនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ
2. ការវះកាត់និងការព្យាបាលកែសម្ផស្ស ឬការព្យាបាលដើម្បីកែលម្អរូបរាង ការព្យាបាលដើម្បីជម្រុះរោម ឬសក់ ឬបណ្តុះសក់ ការផ្លាស់ប្តូរពណ៌ស្បែក ឬពណ៌ភ្នែក លើកលែងការវះកាត់កែសម្រួលមុខងារប្រើប្រាស់បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យ ឬការព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ឬ
3. ការព្យាបាលដែលចាំបាច់ដែលបណ្តាលមកពីផលប៉ះពាល់នៃផ្នែកវិទ្យាសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី ដែលអ្នកត្រូវបានធានារ៉ាប់រងអាចចូលរួមក្នុងទំនាស់ សង្គ្រាម សកម្មភាពរបស់សត្រូវបរទេស ការឈ្លានពាន សង្គ្រាមស៊ីវិល បាតុកម្ម ការបះបោរ កុបកម្ម បដិវត្តន៍ ការផ្តួលរលំរដ្ឋាភិបាលស្របច្បាប់ ការផ្ទុះអាវុធនៃសង្គ្រាម ឬព្រឹត្តិការណ៍ណាមួយដែលប្រហាក់ប្រហែលនឹងព្រឹត្តិការណ៍ដែលបានរៀបរាប់នេះ។ ទាំងនេះរាប់បញ្ចូលទាំងការព្យាបាលទាំងឡាយដែលបណ្តាលមកពីការប្រឈមខ្លួនទៅនឹងហានិភ័យរបស់អ្នកត្រូវបានធានារ៉ាប់រង ដូចជាការទៅកាន់កន្លែងដែលមានចលាចលសង្គម មិនថាក្នុងនាមជាអ្នកឃ្លាំមើល ឬអ្នកទស្សនាក៏ដោយ។ សូមបញ្ជាក់ផងដែរថា ការធានានឹងផ្តល់ជូនសម្រាប់ការព្យាបាលចាំបាច់ដែលបណ្តាលមកពីសកម្មភាពតេរវកម្ម ក្នុងករណីដែលសកម្មភាពនេះមិនបានបណ្តាលមកពីផលប៉ះពាល់ផ្នែកវិទ្យាសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី ឬ
4. ការព្យាបាលដែលបណ្តាលមកពីការចូលរួមនៅក្នុងសកម្មភាពកងទ័ព ឬសកម្មភាពកីឡាជាអាជីព ឬ
5. ការប្រើប្រាស់ឱសថដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាព ឬឱសថដែលស្ថិតនៅក្នុងអំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ នេះមានន័យថា ឱសថទាំងនោះត្រូវទទួលបានអាជ្ញាបណ្ណដោយភ្នាក់ងារឱសថអឺរ៉ុប (the European Medicines Agency) ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅក្នុងសហភាពអឺរ៉ុប ឬពីរដ្ឋបាលផ្នែកឱសថ និងចំណីអាហារនៃសហរដ្ឋអាមេរិក (the US Food and Drug Administration (FDA)) ប្រសិនបើ អ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅកន្លែងផ្សេងទៀតនៅក្នុងសកលលោក ហើយឱសថនោះត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌនៃអាជ្ញាបណ្ណនោះតែប៉ុណ្ណោះ ឬ
6. ការព្យាបាលដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាព ឬការព្យាបាលដែលស្ថិតនៅក្នុងអំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ សម្រាប់ការព្យាបាលដែលមានការទទួលស្គាល់នេះមានន័យថា ជាវិធីសាស្ត្រនិងការអនុវត្តនានាដែលបានឆ្លងកាត់ការសាកល្បងនិងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រយ៉ាងត្រឹមត្រូវ និងត្រូវបានផ្តល់តម្លៃតាងយ៉ាងគ្រប់គ្រាន់នៅក្នុងសៀវភៅវេជ្ជសាស្ត្រដែលបានបោះផ្សាយសម្រាប់គោលដៅជាក់លាក់មួយ ដើម្បីចាត់ទុកថាជាការបង្ហាញពីការព្យាបាលយ៉ាងមានសុវត្ថិភាព និងប្រសិទ្ធភាព ឬ
7. ការព្យាបាលឱ្យមានកូន ការពន្យារកំណើត ឬការបង្កាក់កំណើត ឬគ្រៀវ ឬការព្យាបាលក្នុងការពន្យារកំណើត ការកែភេទ អសមត្ថភាពផ្លូវភេទ ការវះកាត់ព្យាបាលគភ៌ ឬទារកនៅក្នុងផ្ទៃ ឬ
8. រាល់ការចំណាយដែលបង្កឡើងពី ឬពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក (quaratine) ឬ
9. ការព្យាបាលដោយបុគ្គលដែលមិនមែនជាគ្រូពេទ្យ ឬគ្រូពេទ្យដែលមិនមានអាជ្ញាបណ្ណវិជ្ជាជីវៈត្រឹមត្រូវ ឬ
10. ចំណាយដែលមិនមែនសម្រាប់ការព្យាបាលជំងឺដូចជា ថ្លៃសេវាទូរសព្ទ ការជួលទូរទស្សន៍ សារព័ត៌មាន ផលិតផលផ្តល់សំណើមស្បែក គ្រឹមគ្រឿងប្រដាប់សម្រាប់ងូតទឹក អាហារបំប៉ន វីតាមីន ថ្នាំដុសធ្មេញ ឬសាប៊ូ ឬ
11. ចំណាយដែលមិនប្រក្រតី មិនសមហេតុផល មិនមានភាពចាំបាច់ក្នុងការព្យាបាល ក្នុងតំបន់ដែលទទួលការព្យាបាល ឬ
12. ការព្យាបាលប្រឆាំងនឹងភាពជាត់ រួមមានដោយមិនកំណត់ត្រឹមការចង ឬការវះកាត់ទាក់ទងនឹងក្រពះ ការយកចេញនូវកោសិកានិងខ្លាញ់ដែលលើស ឬ
13. ការព្យាបាលដែលជាធម្មតាមិនសម្រាកនៅក្នុងមន្ទីរពេទ្យ ដោយរួមបញ្ចូលទាំងឱសថនិងការរុំរបួស ការប្រឹក្សាយោបល់និងការពិនិត្យតាមដានជំងឺ បូករួមទាំងការពិនិត្យអំឡុងពេលនិងក្រោយពេលមានផ្ទៃពោះ ការព្យាបាលជំងឺផ្លូវចិត្ត ឬ
14. ការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗ ការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានជំងឺក្នុងដំណាក់កាលដំបូងនៃជំងឺដែលគ្មានរោគសញ្ញា លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
15. ការថែរក្សាសុខភាពមាត់ធ្មេញនិងអញ្ចាញធ្មេញ (ឬប្រហាក់ប្រហែល) លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ

16. ការព្យាបាលភ្នែក ឬចក្ខុវិញ្ញាណ ឬ
17. ចំណាយសេវាវេជ្ជសាស្ត្រដែលកើតឡើងក្នុងរយៈពេលនៃការរង់ចាំ លើកលែងតែចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងក្នុងរយៈពេលនៃការរង់ចាំ ដោយអនុលោមទៅតាមករណីមិនធានាដទៃទៀត ឬ
18. ការជំនួសសរីរាង្គខាងក្រៅ (ឧបករណ៍សិប្បនិម្មិត) និងឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ និងឧបករណ៍ពាក់ព័ន្ធនានា ក្រៅពីឧបករណ៍ទាំងឡាយណាដែលជាផ្នែកនៃការវះកាត់ ឬរួមបញ្ចូលក្នុងការព្យាបាល ឬ
19. ចំណាយលើការទទួលសរីរាង្គ ឬជាលិកាពីការបរិច្ចាគ ឬចំណាយរដ្ឋបាលដែលពាក់ព័ន្ធណាមួយ (រួមមាន តែមិនកំណត់ត្រឹមការចំណាយលើការស្វែងរកការបរិច្ចាគ) ឬ
20. ចំណាយបន្ថែមសម្រាប់ការទទួលបានរបាយការណ៍ពេទ្យ ឬការដាក់ពាក្យស្នើសុំទាមទារសំណង ឬចំណាយរដ្ឋបាលផ្សេងៗទៀត ឬ
21. ការព្យាបាលការញៀន (ដូចជាការញៀនគ្រឿងស្រវឹង សារធាតុ ឬថ្នាំញៀន) ឬការប្រើប្រាស់សារធាតុញៀននានាលើសចំណុះ (ដូចជាការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការប្រើប្រាស់សារធាតុ ឬថ្នាំញៀនលើសចំណុះ) ឬតម្រូវការព្យាបាលជំងឺ ឬរបួសនានាដែលបង្កឡើងពីការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការញៀន មិនថាដោយផ្ទាល់ ឬដោយប្រយោលឡើយ ឬ
22. ចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) និង/ឬជំងឺដែលពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) ដោយរាប់បញ្ចូលទាំងជំងឺអេដស៍ ឬរោគសញ្ញារបស់ជំងឺអេដស៍ និង/ឬរោគសញ្ញានានាដែលបំប្លែងពីរោគសញ្ញានៃជំងឺអេដស៍នេះ លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
23. ការចាក់ថ្នាំបង្ការ ក្រៅពីការចាក់ថ្នាំបង្ការលើកដំបូងសម្រាប់ទារកទើបនឹងកើតដែលបានធានាក្រោមអត្ថប្រយោជន៍លើការសម្រាលកូន និងការថែទាំទារកទើបនឹងកើតដូចមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
24. ការសម្រាលកូននិងការថែទាំទារកទើបនឹងកើត លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
25. គ្រែបន្ថែមសម្រាប់អាណាព្យាបាល ឬអ្នកកំដរ ខណៈដែលអ្នកត្រូវបានធានារ៉ាប់រងចូលសម្រាកក្នុងមន្ទីរពេទ្យ លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
26. ការថែទាំរបស់គិលានុបដ្ឋាកតាមផ្ទះលុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
27. ការថែទាំជំងឺផ្លូវចិត្តលុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
28 សេវាកម្មថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយលុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
29. ចំណាយណាមួយដែលកើតឡើងខណៈអ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា រយៈពេល 90 (កៅសិប) ថ្ងៃជាប់គ្នា ឬច្រើនជាងនេះ ក្នុងអំឡុងពេល 1ឆ្នាំនៃបណ្ណសន្យារ៉ាប់រង ឬ
30. ចំណាយដែលអ្នកត្រូវបានធានារ៉ាប់រងបានទូទាត់ប្រាក់ត្រលប់មកវិញពីរបបសន្តិសុខសង្គម (ប.ស.ស) ឬអត្ថប្រយោជន៍ផ្សេងទៀត ឬធានារ៉ាប់រងផ្សេងទៀតរួចហើយ។ ក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះតែថ្លៃព្យាបាលដែលមិនទាន់បានទូទាត់ប៉ុណ្ណោះ។

ការិយាល័យកណ្តាល - ភ្នំពេញ
អគារ ជីអាយអេ ថៅអឺរ ជាន់ទី**31** ផ្លូវសុភមង្គល ភូមិ**14** សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

សាខាសៀមរាប
អគារលេខ **29**និង**30**
ផ្លូវហ្សាលដីហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

សាខាបាត់ដំបង
ផ្ទះលេខ**2-6** ផ្លូវលេខ**3** ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ខេត្តបាត់ដំបង

សាខាកំពង់ចាម
ភូមិ**15** សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

សាខាកំពត
ផ្លូវលេខ**700** ភូមិ**1**ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA